## ឯកសារប្រវត្តិសាស្រ្ត



ទិដ្ឋភាពមូលដ្ឋានកងទ័ពយៀកកុង-យៀកណាមខាងជើង
នៅក្នុងខេត្តរតនគិរី

# ការសម្ងាត់

## សេចក្តីរាយការណ៍សម្ងាត់បោះពុម្ពផ្សាយក្រោមបញ្ជា នៃសម្តេចសីហនុក្នុងទស្សនាវដ្តីប្រចាំខែ<ឡឹសង្គម>

( លេខខែមិថុនា ឆ្នាំ១៩៦៩ )

## សម្ភាសន៍នៃលោកឧត្តមសេនីយ៍ឯក លន់_នល់ ជាមួយលោកង្វៀង_ធួង, រដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងលោកង្វៀង_វ៉ាន់ហ៊ីវ, រដ្ឋទូតនៃរណសិរ្សរំដោះជាតិ

( បកប្រែក្រៅផ្លូវការ )

ដកស្រង់ចេញពី <ឯកសារស្តីអំពីអំពើឈ្លានពាន នៃយៀកកុង-យៀកណាមខាងជើងមកលើកម្ពុជា-ឆ្នាំ១៩៧០> បោះពុម្ពផ្សាយដោយក្រសួងឃោសនាការជាតិក្រុងភ្នំពេញ

( កកន ÷ ថ្មីៗ (ថ្ងៃទី២-៣ តុលា ២០០៣) នៅក្នុង website របស់ស្តេចសីហនុ គេសង្កេតឃើញស្តេចសីហនុចុះផ្សាយនូវក្របសៀវភៅ <ព្រំដែនកម្ពុជា> សរសេរដោយលោក **សារិន_ឆាក** ដែលបានបោះពុម្ពផ្សាយកាលពីឆ្នាំ១៩៦៦ ។ វត្ថុបំណងនៃការលើកសៀវភៅនេះឡើង គឺស្តេចសីហនុចង់រលើកឲ្យដឹងថា ព្រះអង្គក៏ធ្លាប់បាន<ចាប់អារម្មណ៍>នៅក្នុងបញ្ហាព្រំដែនខ្មែរដែរ គឺពុំមែន<ព្រងើយកន្តើយ> ចេះតែ<ហេកហាក>ឲ្យតែផុតៗរួចពីមុខពីមាត់នោះទេ ។ អត្ថបទប្រែសំរួលក្រៅផ្លូវការ ដែលខ្ញុំ<លីឡើប>នឹងចុះជូននៅខាងក្រោមនេះ គឺជា<ឯកសារប្រវត្តិសាស្ត្រ>មួយបញ្ជាក់ឲ្យឃើញអំពី<កំហុស>របស់ស្តេចសីហនុ នៅក្នុងអំពើអនុញ្ញាតរបស់ព្រះអង្គ ឲ្យយួនដែលជាសត្រូវសួរពូជរបស់ខ្មែរ ដែលស្តេចសីហនុក៏ធ្លាប់បានដឹងរួចទៅហើយ តាមរយៈសៀវភៅរបស់លោក **សារិន_ឆាក** ដែរនោះ ផ្តើនប្រើប្រាស់ទឹកដីខ្មែរធ្វើជាមូលដ្ឋានទ័ពរបស់វា ។ មកដល់ដំណាក់ការ មិនអាចបណ្តេញយៀកកុង-យៀកណាមខាងជើងឲ្យដកថយចេញពីទឹកដីខ្មែរ រួមជាមួយបញ្ហាសេដ្ឋកិច្ចធ្ងន់ធ្ងរចោទឡើងនៅក្នុងស្រុកផង ស្តេចសីហនុក៏សំរេចទម្លាក់អំរែកនេះទៅលោកលន់-នល់ រួចហើយប្រមូលប្រពន្ធប្រមូលកូនរត់ចោលស្រុក ។ នេះហើយជាចំណុចចាប់ផ្តើមនៃ <ព្រឹត្តិការណ៍១៨ មីនា ឆ្នាំ១៩៧០> ។ មកដល់ថ្ងៃនេះទៀត ខ្ញុំនៅតែមើលឃើញថា ដោយសារទំនាស់ផលប្រយោជន៍ផ្ទាល់ខ្លួន ជាពិសេសព្រះរាជបល្ល័ង្ក ស្តេចសីហនុនៅតែបន្តធ្វើជា <ហេកហាក> ដ៏-ដែលអំពីបញ្ហាព្រំដែនខ្មែរ-យួននេះ ) ÷



CENTRE D'ÉTUDE DES PAYS D'EXTRÊME-ORIENT
ASIE DU SUD-EST

— I —

LES FRONTIERES DU CAMBODGE

TOME I

Les frontières du Cambodge avec les anciens pays de la Fédération Indochinoise : le Laos et le Vietnam (Cochinchine et Annam)

PAR

SARIN CHHAK

Docteur ès Sciences Politiques
Représentant permanent du Cambodge à l'U. N. E. S. C. O.

Préfaces de :

S. A. R. le Prince NORODOM SIHANOUK
Chef de l'État du Cambodge

et de

Paul REUTER
Professeur à la Faculté de Droit et des Sciences Économiques de Paris

PARIS
LIBRAIRIE DALLOZ
11, rue Soufflot, 11
1966

រូបក្របសៀវភៅ

« តម្រូវតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់ឲ្យជួបជាមួយលោក ង្វៀង-ធួង និងលោក ង្វៀង-វ៉ាន់ហ៊ីវ ជារដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងរដ្ឋទូតនៃរណសិរ្សរំដោះជាតិ ដើម្បីទាញចំណាប់អារម្មណ៍លើស្ថានភាពដ៏ធ្ងន់ធ្ងរបង្កឡើងដោយ ÷

ក- អំពើកាន់កាប់នៅតាមតំបន់ខ្លះនៃទឹកដីរបស់យើង ដោយកងទ័ពយៀកណាមខាងជើងនិងរណសិរ្សរំដោះជាតិ ។

ខ- អំពើវាយប្រហារដោយចំហនៃកងទ័ពទាំងនេះ ប្រឆាំងមកលើកងទ័ពរបស់យើង ។

គ- ការគាំទ្រកាន់តែសកម្មឡើងៗ ដល់ពួកខ្មែរក្រហម ។

ទូលព្រះបង្គំមានកិត្តិយសទូលថ្វាយដល់សម្តេចឪ ដើម្បីព្រះអង្គបានជ្រាបដឹង អំពីឥស្សរជនទាំងពីររូប ដែលបានហៅចូលមកប្រជុំកាលពីថ្ងៃទី២៨ ឧសភាថ្មីៗនេះ នៅទីស្តីការប្រធានក្រុមប្រឹក្សារាជរដ្ឋាភិបាល ។

តទៅនេះគឺសេចក្តីអធិប្បាយ ដែលព្រះរាជបំរើបានធ្វើជាមួយឥស្សរ

ជននិមួយៗនេះ ផ្តោតទៅលើកត្តាបីចំណុច (ដូចមាននៅខាងក្រោម) ដែលបង្កើតឲ្យមានជាស្ថានភាពធ្ងន់ធ្ងរ ។ ព្រះរាជបំរើបានធ្វើឲ្យដឹងជាដំបូងអំពីបានទទួលនូវព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់ពីព្រះអង្គ ដើម្បីឲ្យពួកគេចាប់អារម្មណ៍ទៅលើអំពើដ៏ធ្ងន់ធ្ងរ ដែលពួកគេបានធ្វើមកលើកម្ពុជានាពេលបច្ចុប្បន្ននេះ ។

I- ការកាន់កាប់តំបន់ខ្លះដោយកងទ័ពវៀតណាមខាងជើង និងរណសិរ្សរំដោះជាតិ ៖

ទូលព្រះបង្គំបានប្រកាសទៅពួកគេឲ្យដឹងថា ៖

«ចាប់តាំងពីមួយរយៈពេលមកហើយ, យើងបានធ្វើការកត់សម្គាល់ឃើញវត្តមាននៃកម្លាំងទ័ពរបស់លោក កំពុងប្រែក្លាយទៅជាអំពើកាន់កាប់យ៉ាងពិតប្រាកដ នៅក្នុងតំបន់ជាច្រើននៃទឹកដីរបស់យើង ។

១/- ទិសខាងជើងនៃប្រទេសកម្ពុជា (ខាងផ្នែកខេត្តរតនគិរី) ៖

ភូមិភាគនៃខេត្តស្ទឹងត្រែងនិងរតនគិរី អាចទុកថាបានកាន់កាប់ដោយយោធានិងដោយរដ្ឋបាលពីសំណាក់កងទ័ពរបស់លោក ។ ចំណុចខ្លះស្ថិតជ្រៅខាងក្នុងទឹកដីរបស់យើង, យ៉ាងឆ្ងាយពីព្រំដែន, ឧទាហរណ៍ នៅបកែវចម្ងាយសាមសិបគីឡូម៉ែត្រពីព្រំដែនទិសខាងកើត, នៅបាកាប់ចម្ងាយមួយរយគីឡូម៉ែត្រពីព្រំដែនទិសខាងជើង, នៅត្រង់បង្គោលគីឡូម៉ែត្រលេខ១១ លើផ្លូវជាតិលេខ១៩ ចម្ងាយជាច្រើនរយគីឡូម៉ែត្រ ។ ភស្តុតាងនៃការកាន់កាប់ទាំងអស់នេះមានយ៉ាងច្រើន ហើយខ្ញុំសុំឲ្យលោកចាត់វិធានការជាចាំបាច់ផង ។

- ក្នុងផ្នែកមួយនោះ មានបងប្អូនខ្មែរលើបានត្រូវបង្ខំចេញចាកពីភូមិនៅក្រោមបញ្ជារបស់ពួកលោក ដើម្បីពង្វាងចេញពីការត្រួតត្រារបស់យើង ។ នៅពេលសម្តេចសុខចិត្តធ្វើព្រះរាជទស្សនកិច្ចបកែវ, ភាគច្រើននៃបងប្អូនខ្មែរលើបានចូលទៅនៅក្នុងព្រៃ ជាមួយកងទ័ពរបស់ពួកលោករួចទៅហើយ ។

- នៅបកែវ, ពេលបញ្ចាំងភាពយន្តកណ្តាលវាលមួយ រៀបចំឡើងក្រោមព្រះរាជបញ្ជារបស់សម្តេចព្រះប្រមុខរដ្ឋ ក្នុងព្រះរាជដំណើរទស្សនកិច្ចចុងក្រោយបង្អស់ក្នុងខេត្តនេះ, កងទ័ពរបស់ពួកលោកបានបាញ់រះទៅលើប្រជារាស្ត្រដែលមកមើលដ៏មានចំនួនយ៉ាងច្រើន ដើម្បីបញ្ចៀសពួកគេមិនឲ្យមកចូលរួមសប្បាយនៅក្នុងពិធី ដែលរៀបចំឡើងក្រោមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់នៃសម្តេចសហជីវិន ។

ក្រៅអំពីនេះ, កងទ័ពរបស់យើង ស្ថិតនៅចម្ងាយ២គ.ម.ពីទីនោះពុំអាចចេញរួចពីទីតាំងរបស់ពួកគេ ក្រោមការវាយប្រហារបាញ់សម្លាប់នៃកងទ័ពរបស់ពួកលោក ។ ទង្វើនេះបញ្ជាក់ឲ្យឃើញនៅក្នុងសេចក្តីរាយការណ៍ប្រចាំថ្ងៃថ្លែងប្រាប់ដោយបងប្អូនខ្មែរលើដែលបានរត់ចេញមក និងពីសំណាក់ប្រជាពលរដ្ឋរស់នៅទីនោះ ដែលយើងខ្ញុំបានទទួល ។

- នៅពេលរៀបចំរដ្ឋបាលរបស់យើងឡើងវិញនៅបខាំ, ដែលជាសកម្មភាពថ្លែងបញ្ជាក់ជាសាធារណដោយសម្តេចផ្ទាល់ នៅក្នុងឱកាសសន្និសិទសារព័ត៌មានចាក់ផ្សាយតាមវិទ្យុរបស់ព្រះអង្គ, អំពីការវាយប្រហារបញ្ចៀសកងទ័ពយើងចាកចេញពីបកែវ ដោយបណ្តាលឲ្យស្លាប់និងខូចខាតនូវរបស់របរដូចជា ៖ គ្រឿងយន្ត, រថក្រោះ, រថយន្តត្រូវខូចខាតពីការដាក់ផ្ទុះដោយគ្រាប់មីន, ពីការឡោមព័ទ្ធ, ពីការវាយប្រហារ និងពីការបាញ់យាយីពីសំណាក់កងទ័ពរបស់ពួកលោក ។

គឺនៅក្នុងការឡោមព័ទ្ធនេះហើយ ដែលយើងបានសម្លាប់ទាហាន២នាក់ខាងពួកលោក ព្រមទាំងបងប្អូនខ្មែរលើ២នាក់ (យោងតាមព្រះបន្ទូលរបស់សម្តេចឪនៅក្នុងសន្និសិទសារព័ត៌មាន) ។

ក្បួនរថយន្តនៃមេបញ្ជាប្រតិបត្តិការនិងជាមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ក៏បានទទួលរងនូវគ្រាប់កាំភ្លើងនិងត្រូវផ្ទុះដោយគ្រាប់មីនផងដែរ ។ ហើយយើងក៏ពុំបានធ្វើអ្វីទាំងអស់ ក្រៅអំពីឆ្ពោះទៅរកគោលដៅរបស់យើង ដែលចាត់ថាជាអំពើដ៏ឆាឆៅបញ្ចៀសយើងមិនឲ្យទៅកាន់បខាំ តាមផ្លូវជាតិលេខ១៩ ។

- នៅបាកាប់និងទៅទិសខាងជើង, នៅលើច្រាំងខាងស្តាំ និងខាងឆ្វេងនៃស្ទឹងសេសែន, កងទ័ពរបស់យើងបានប៉ះទង្គិចគ្នានឹងកងទ័ពរបស់ពួកលោក ។ នៅក្នុងពេលពើបប្រយុទ្ធគ្នានោះ ទាហានខាងយើងបានស្លាប់ម្នាក់ ហើយយើងចាប់បានឈ្លើយបីនាក់ ដែលមានឯកសារជាប់ក្នុងខ្លួនសរសេរជាភាសាវៀតណាម ។ ពួកគេបានប្រកាសឲ្យដឹងថា ពួកគេចេញមកពីវៀតណាមខាងជើង ហើយបានមកនៅក្នុងតំបន់នេះអស់ចំនួនជាងមួយឆ្នាំមកហើយ ។ នេះគឺជាការរុលទៅមុខយ៉ាងសំខាន់នៃកងទ័ព ស្ថិតនៅចម្ងាយដប់គីឡូម៉ែត្របណ្តោយទៅទិសខាងជើង ។

- នៅត្រង់បង្គោលគីឡូម៉ែត្រ១១ លើផ្លូវជាតិលេខ១៩ (ចំណុចមួយស្ថិតនៅក្នុងទឹកដីយើង) ព្រមទាំងនៅទីកន្លែងជាច្រើនទៀត, ក្បួនដឹកស្បៀងរបស់យើងតែងពើបប្រទះការបាញ់មកលើពីកងទ័ពរបស់លោក

គ្មានការពន្យល់ដល់យើងទាល់តែសោះ ថាហេតុអ្វីបានជារឿងរ៉ាវកើតឡើងយ៉ាងដូច្នេះ, ចាប់ពីថ្ងៃទី២២ មេសា ឆ្នាំ១៩៦៩ មកដល់ថ្ងៃទី២២ ឧសភា ឆ្នាំ១៩៦៩, សកម្មភាពនៃកងទ័ពរបស់លោកប្រឆាំងយើង បានកើនឡើងដល់ទៅ៣៥ដង ។ យើងមានការខាតបង់ដល់ស្លាប់ ហើយនិងមានការខូចខាតរថយន្ត ។

២/- នៅមណ្ឌលគិរី ៖

ការកាន់កាប់ដោយកងទ័ពរបស់លោក លើចំណុចមួយចំនួននៃទឹកដីរបស់យើង ដែលកន្លែងខ្លះជាឃ្លាំង, ជាគិលានុបដ្ឋាន និងជាសេនាធិការដ្ឋានប្រតិបត្តិការយ៉ាងពិតប្រាកដ ។ ពួកកងទ័ពរបស់លោកកាន់កាប់តំបន់នោះយ៉ាងជាក់ច្បាស់, ប្រើប្រាស់ច្បាប់របស់ខ្លួន ដោយតម្រូវឲ្យអាជ្ញាធរស៊ីវិលនិងយោធារបស់យើង ត្រូវសុំនូវការអនុញ្ញាតជាមុន ដើម្បីឆ្លងកាត់ទីកន្លែងនោះ ។

៣/- នៅក្នុងខេត្តកំពង់ចាម ៖

ការកាន់កាប់ត្រួតត្រាមិនត្រឹមតែនៅតាមតំបន់ព្រំដែនប៉ុណ្ណោះទេ តែរហូតចូលមកដល់កន្លែងយ៉ាងជ្រៅថែមទៀតផង ។ មានកន្លែងមួយនោះមានមូលដ្ឋាន និងប៉ុស្តិ៍ឆែកឆេរ ។ល។ អង្គការភស្តុភាររបស់លោកបានធ្វើឲ្យប្រជាពលរដ្ឋរស់នៅត្រង់កន្លែងនោះ ក្លាយទៅជាទីកន្លែងរត់ពន្ធ ។ ទោះបីយើងបានធ្វើសំណូមពរជាមិត្តភាព នៅរាល់ពេលយើងចាប់បានរបស់របររត់ពន្ធ ឬទោះបីមានការពិភាក្សាគ្នាជាមួយពួកអ្នកតំណាងរបស់លោកយ៉ាងណាក៏ដោយ ក៏ស្ថានការណ៍នៅតែដដែល ។

៤/- នៅក្នុងខេត្តព្រៃវែងនិងខេត្តស្វាយរៀង ៖

នៅទីនោះក៏ដូចគ្នាដែរ, គេឃើញមានប៉ុស្តិ៍ឆែកឆេរ, មូលដ្ឋាន និងឯកភាពកងទ័ព ។ យើងបានប្រកាសឲ្យដឹង អំពីអាជ្ញាធររបស់យើង ជាច្រើនលើក សុំឲ្យកងទ័ពរបស់លោកដកថយចេញពីចំណុចកាន់កាប់ជាយូរពេលមកហើយ និងសុំឲ្យបោះបង់ទឹកដីរបស់យើង ដោយយោងតាមច្បាប់អន្តរជាតិ និងតាមការប្រកាសជាឯកច្ឆន្ទនៃមេដឹកនាំរបស់លោក ។

តែផ្ទុយទៅវិញ កងទ័ពរបស់លោកមិនត្រឹមតែមិនព្រមចាកចេញប៉ុណ្ណោះទេ ពួកគេថែមទាំងបាញ់រះមកលើកងទ័ពយើង... (នៅមានត)

# កម្ពុជាគាំទ្រយួនខាងជើង

**អត្ថបទដកស្រង់ចេញពី**
**សៀវភៅរបស់លោកសោម-សេកកុមារ**
**«វិបត្តិកម្ពុជានិងទំនាក់ទំនងជាមួយបរទេស»**

នេះជាចំណាងជើងនៃអត្ថបទរបស់ទីភ្នាក់ងារ UPI ដែលផ្តល់ដំណឹងពីក្រុងភ្នំពេញ នៅថ្ងៃទី១២ សីហា ១៩៦៦ ដូចតទៅ ៖ ក្នុងឱកាសសន្និសិទសារពត៌មានមួយ, ស្តេចសីហនុបានប្រកាសថា លើកិច្ចការផ្ទៃក្នុងរបស់យួន កម្ពុជាគាំទ្រទាំងស្រុងដល់ទស្សនៈរបស់ហាណូយនិងរណៈសិរ្សរំដោះយួនខាងត្បូង ដែលសំរេចចិត្តចរចាឬប្រយុទ្ធឥតឈប់ឈរ ។ សីហនុបន្ថែមថា ដំណោះស្រាយតែមួយគត់របស់យួនគឺ គោរពកិច្ចព្រមព្រៀងហ្សឺណែវ, មានន័យថា ជន្លៀសកងទ័ពអាមេរិកាំងចេញពីយួនខាងត្បូង តាមវិធីសំរាប់ឲ្យប្រជាជនយួនសំរុះសំរួលគ្នា ។ សីហនុបានចាត់ទុកជា <ឆាកល្ខោន> នូវគំរោងសន្និសិទនៃរដ្ឋនៅអាស៊ីអំពីបញ្ហាយួន ដែលសំរេចធ្វើឡើងក្នុងពេលនោះដោយហ្វីល្លីពីន, ម៉ាឡេស៊ី និងសៀម ។ សីហនុបញ្ជាក់ថា «កម្ពុជាដាច់ខាតមិនចូលរួម» ( **Le Monde, 13 Aôut 1966** ) ។

កិច្ចព្រមព្រៀថស្តីពីព្រំដែននឹងអាចត្រូវសំរេចឡើងនៅមុនដំណាច់ឆ្នាំ រវាងកម្ពុជានិងរណសិរ្សយៀកកុង ទោះបីមានការគំរាមពីព្រៃនគរក៏ដោយ ។ សីហនុនិយាយថា «កិច្ចព្រមព្រៀងនេះ នឹងស្ថិតនៅជាលិខិតបញ្ជាក់រវាងអ្នកតំណាង ដែលគេពុំអាចជំទាស់បានរបស់ប្រជាពលរដ្ឋខ្មែរនិងយួន» ( **Le Monde, 18 Juillet 1966** ) ។

សូមជំរាបបញ្ជាក់ថា ត្រាន់-ប៊ូគៀមនេះ បានជ្រៀតចូលមកកម្ពុជាតាំងពីឆ្នាំ១៩៦៣ ជាមួយពួកមេដឹកនាំនៃរណសិរ្សយៀកកុងដទៃទៀតព្រោះថា ចាប់ពីឆ្នាំ១៩៥៥, ពិតមែនតែបារម្ភជាមួយពួកយួនយៀកមិញ, សីហនុបានអនុញ្ញាតឲ្យពួកជឿនលឿននិយមយួនមួយចំនួន ភៀសខ្លួនមកកម្ពុជា ។ តាមពិត, តាំងពីឆ្នាំ១៩៤៦, គៀម ជាប្រតិភូនៃគណៈកម្មាធិការមជ្ឈឹមរបស់ <លៀនវៀត>, ហើយព្រមជាមួយគ្នា ជានាយករងក្នុងសេវាសេដ្ឋកិច្ចនៃរដ្ឋាភិបាលបណ្តោះអាសន្នរបស់ហូ-ជីមិញ ។ ពេលមានការបែងចែកប្រទេសយួនត្រឹមខ្សែស្របទី១៧, គៀមបានស្ម័គ្រចិត្តទៅយួនខាងជើង, ប៉ុន្តែចាប់ពីឆ្នាំ១៩៦០, គៀមបានត្រឡប់ដោយសម្ងាត់មកយួនខាងត្បូងវិញ, ក្រោយការបង្កើតរណសិរ្សរំដោះយៀកកុងដោយហូ-ជីមិញនៅឆ្នាំ១៩៥៩ ។ នៅខែកក្កដា១៩៦៣, ក្នុងភូមិគ្រឹះមួយនៅឆ្នេរកែប, គៀមបានទទួលអ្នកសារពត៌មានបារាំង, ហ្ស៊ែកហ្ស៊-ហ្សាហ្ស៊ាំជ័, តាមរយៈបទសម្ភាសន៍មួយដែលត្រូវបានចុះផ្សាយក្នុងសារពត៌មានឡឺម៉ុងដ៍ នៅថ្ងៃទី២៩ សីហា ១៩៦៣ ។ បន្ទាប់មក នៅឆ្នាំ១៩៦៥, ជាផ្លូវការគេបានឃើញត្រាន់ប៊ូគៀមនៅភ្នំពេញ ក្នុងឋានៈជាអនុប្រធាននៃគណប្រតិភូរបស់<រណសិរ្សយៀកកុង> ដែលបានជូនដំណើរដោយ វិញ-តាន់ផាត, ជាប្រធានគណប្រតិភូ, ក្នុងឱកាសសន្និសិទ<ប្រជាជនឥណ្ឌូចិន> ដែលរៀបចំឡើងដោយសីហនុ (**André Tong,"Sihanouk, la fin des illusions". pp. 122-123**) ។

ទាំងនេះប្រហែលអាចបញ្ជាក់បានថា សីហនុមានបំណងយ៉ាងប្តូរផ្តាច់ដើម្បីឲ្យរណសិរ្សយៀកកុង យកជ័យជំនះលើរដ្ឋាភិបាលស្របច្បាប់នៅព្រៃនគរ ដែលគាំទ្រដោយស.រ.អា. ។ ហើយបើជាការពិតមែន គឺគំ



ក្នុងថ្ងៃទី២៨ ឧសភា ១៩៦៥, នរោត្តម-សីហនុប្រគល់អំណោយទៅត្រាន់-ប៊ូគៀម ដែលជាតំណាងនៃរណសិរ្សយៀកកុងប្រចាំកម្ពុជា ។ រូបថតដកស្រង់ពី **Collection particulière de Bernard Hamel (Historia, Juin 1979, No.391, p.93)**



ស្តេចសីហនុនិងត្រាន់-ប៊ូគៀម មេយៀកកុងនៅកម្ពុជា

និតមានះរបស់ស្តេចសីហនុនេះតែម្តង ដែលបាននាំឲ្យប្រជារាស្ត្រខ្មែរនៅព្រំដែនខាងកើតរងទុក្ខវេទនា រហូតដល់ប្រទេសខ្មែរទាំងមូល ត្រូវឆេះសន្ធោរសន្ធៅដោយភ្លើងសង្គ្រាម គឺប្រទេសខ្មែរដែលពិសេសបំផុតថាខ្លួន <អព្យាក្រឹត> ។



ប៉ុន្តែ, មានការប្រែប្រួលដ៏ហួសពីការស្មានមួយ ក្នុងនយោបាយក្រៅប្រទេសរបស់ខ្មែរ ដែលទីភ្នាក់ងារ AFP ជូនដំណឹងពីភ្នំពេញនៅថ្ងៃទី៩កញ្ញា១៩៦៦ដូចតទៅ «ដើម្បីស្វែងរកការស្រុះស្រួលជាថ្មីជាមួយសៀម កម្ពុជាបានត្រៀមខ្លួនជាស្រេចដើម្បីបញ្ជូនមន្ត្រីការទូតទៅបាងកក», នេះជាសេចក្តីប្រកាសរបស់សីហនុ ដោយបន្ថែមថា «គាត់គ្រាន់តែបានស្នើរកការផ្សព្វផ្សាយនូវសេចក្តីប្រកាសរួមរវាងខ្មែរ-សៀម ដែលបញ្ជាក់ពីការគោរពទៅវិញទៅមកដល់ព្រំដែនបច្ចុប្បន្ន» ។ សីហនុបន្តថា «បញ្ហាខ្មែរសេរីគ្មានសារ:សំខាន់ទាល់តែសោះ», ដោយបញ្ឆិតបញ្ឆៀងទៅរកក្រុមសឺង-ង៉ុកថាន់ ដែលតាំងមូលដ្ឋានក្នុងប្រទេសសៀម ( Le Monde, 10 Septembre 1966 ) ។

មកដល់ថ្ងៃទី២០ កុម្ភ:១៩៦៧, ឧប្បត្តិហេតុធំមួយបានកើតឡើងទៅទល់ដែនខ្មែរនៃខេត្តស្វាយរៀង ។ ទីភ្នាក់ងារ AFP បានរាយការណ៍ពីទីក្រុងញូវយ៉កនៅថ្ងៃទី២៨កុម្ភ:ដូចតទៅ «តំណាងកម្ពុជាប្រចាំអ.ស.ប. បានដាក់សេចក្តីជូនពត៌មាន ទៅប្រធានក្រុមប្រឹក្សាសន្តិសុខ ដោយតវ៉ាប្រឆាំង «ការឈ្លានពានធ្ងន់ធ្ងរមកលើទឹកដីខ្មែរ ដោយទ័ពជើងគោកអាមេរិកាំង-យួនខាងត្បូង ដែលគាំទ្រគគ្រឹកគគ្រេងដោយកងអាកាសចរណ៍» ។ យោងលើអត្ថបទនេះ, ពលទាហានប្រហែល២០០នាក់ ដែលចុះពីឧទ្ធម្ភាគចក្រ៦០ប្លយគ្រឿង បានសំរុកចូលចម្ងាយ៦០០ម៉ែត្រមកក្នុងទឹកដីខ្មែរ ។ ដោយមានការគាំទ្រពីយន្តហោះ៩គ្រឿង, ក្រុមទាហានទាំងនេះបានទង្គិចជាមួយកងទ័ពខ្មែរ ដែលត្រូវស្លាប់ពីរនាក់និងរបួសបីនាក់ ។ លុះស្អែកឡើង យន្តហោះបានបាញ់រះនិងទំលាក់គ្រាប់បែកលើភូមិដូងក្នុងស្រុករមាសហែកនៃខេត្តស្វាយរៀងនេះទៀត ( Le Monde, 1 Mars 1967 ) ។

## សារលិខិតមិត្តភាពពីហូ-ជីមិញចំពោះស្តេចសីហនុ

នេះជាចំណងជើងនៃអត្ថបទរបស់ទីភ្នាក់ងារ AFP ដែលរៀបរាប់ពីក្រុងភ្នំពេញនៅថ្ងៃទី១៧មេសា១៩៦៧ដូចតទៅ ៖ «ទោះបីជាពួកសត្រូវចក្រពត្តិអាមេរិកាំងបង្កើនការប្រឹងប្រែងមួយជាពីរ ដើម្បីដាក់ការត្រួតត្រាអាណានិគម លើប្រជាជនឥណ្ឌូចិនក៏ដោយ ក៏ប្រជាជននេះដែលរួបរួមគ្នាយ៉ាងជិតស្និទ្ធ ប្រាកដជានឹងដណ្តើមបានជ័យជំនះផ្តាច់ព្រ័ត ដើម្បីសុភមង្គលរបស់ខ្លួន នៅក្នុងឯករាជភាពនិងសេរីភាពពិតប្រាកដ», នេះជាសេចក្តីប្រកាសរបស់ប្រធានហូ-ជីមិញ តាមសារលិខិតសំដែងសព្ទសាធុការចំពោះស្តេចសីហនុ នាឱកាសបុណ្យចូលឆ្នាំខ្មែរ ។ ប្រធានហូដែល «បញ្ជាក់ជាថ្មី អំពីសាមគ្គីភាពទាំងស្រុងរបស់ប្រជាជនយួន ប្រឆាំងពួកឈ្លានពានអាមេរិកាំង»។ [ នៅឯហាណូយ, សារពត៌មាន <ញើងយ៉ើង> បោះពុម្ពផ្សាយអត្ថបទថ្លែងសរសើរកម្ពុជា ។ សក្ខីភាពជាមិត្តភាពនេះជួបប្រទះអត្ថន័យរបស់ខ្លួនក្នុងព្រឹត្តិការណ៍ ដែលស្តេចសីហនុប៉ះទង្គិចជាមួយក្រុមកុម្មុយនិស្តប្រដាប់អាវុធ ដែលគាត់ចោទជា«ខ្មែរយៀកមិញ» ។ សីហនុបានរំលឹកពីអាទិត្យមុនថា នៅឆ្នាំ១៩៥៣និង១៩៥៤ ពួកកុម្មុយនិស្តយួនបានធ្វើអន្តរាគមន៍នៅកម្ពុជា ។ ទំនាក់ទំនងរវាងហាណូយនិងភ្នំពេញ ហាក់ដូចជាពុំមានការប៉ះពាល់ជាមួយប្រកាសថ្មីៗនេះទេ ] ។៚

ឯកសារប្រវត្តិសាស្ត្រ

# ការរកឃើញជំរកយៀកកុងបណ្ដាលឱ្យខឹងសម្បារដល់ស្ដេចសីហនុ

By George McArthur and Horst Faas
Associated Press
Thursday, November 30, 1967

<u>កកន</u> ៖ អត្ថបទនេះបានចុះផ្សាយដោយសារពត៌មានជប៉ុនមួយឈ្មោះ <THE YOMIURI> និងធ្វើការចម្លងទុកជាឯកសារចុះនៅក្នុង <LIVRE BLANC> SUR L'AGRESSION VIETCONG ET NORD-VIETNAMIENNE CONTRE LA REPUBLIQUE KHMERE (1970-1971)

ការរកឃើញជំរកយៀកកុងស្ថិតនៅចម្ងាយ៩ម៉ែល៍(៨គ.ម.) ក្នុងទឹកដីខ្មែរ បានបណ្ដាលឲ្យជនអព្យាក្រិតនិយមគឺស្ដេចនរោត្ដម-សីហនុ ខឹងសម្បារយ៉ាងខ្លាំង និងធ្វើឲ្យគេមានមន្ទិលសង្ស័យទៅលើចម្លើយបដិសេធទាំងប៉ុន្មានពេលកន្លងមករបស់ព្រះអង្គ អំពីការផ្ដល់ជំរកដល់កងកម្លាំងយួនកុម្មុយនិស្ត ។

ព្រះអង្គបានត្រូវគេរាយការណ៍ ទាក់ទងនឹងការរកឃើញដោយពួកអ្នកកាសែតអាមេរិកាំង ថាជាអំពើប្រឌិតនិងជាផ្នែកមួយនៃការឃោសនាប្រឆាំងព្រះអង្គ ពីសំណាក់កាសែតអាមេរិកាំង ។

ជំរកយៀកកុងដែលទើបប្រើប្រាស់ថ្មីៗនេះ បានត្រូវប្រទះឃើញនៅតាមព្រំដែន ទល់មុខនឹងកន្លែងដែលគេហៅ <War Zone C> ស្ថិតនៅប្រហែលចម្ងាយ៧០ម៉ែល៍ (១១០គ.ម.) ទិសខាងជើងឆៀងខាងលិចទីក្រុងសៃហ្គង ។

ជំរកនេះបានរកឃើញដោយលោក George McArthur អ្នកឆ្លើយឆ្លងប្រចាំទីភ្នាក់ងារពត៌មាន Associated Press និងលោក Horst Faas ជាអ្នកថតរូប ព្រមទាំងលោក Ray Herndon អ្នកឆ្លើយឆ្លងប្រចាំទីភ្នាក់ពត៌មាន United Press International ។ ជំរំបានត្រូវប្រើប្រាស់ជាច្រើនខែមកហើយ ហើយដែលសំខាន់បំផុតនោះ ប្រហែលប្រើជាកន្លែងតាំងជំហរ សំរាប់ធ្វើការវាយប្រហារកាលពីដើមខែនេះ ទៅលើខេត្តឡុកនិញ ដែលស្ថិតនៅចម្ងាយតែ៩ម៉ែល៍ (១៩គ.ម.) ប៉ុណ្ណោះពីទីនេះ ។

ព្រះអង្គម្ចាស់, ជនមានបន្ទូលឥតសំចៃដៃ ដែលបានស្ដីបន្ទោសសហរដ្ឋអាមេរិកថាជាអ្នកឈ្លានពានប្រទេសវៀតណាម និងដែលបានផ្ដល់នូវការគាំទ្រជាសាធារណៈដល់ពួកយៀកកុង បានរាយការណ៍ប្រាប់ទៅពួកអ្នកកាសែតជិតស្និទ្ធព្រះអង្គថា នេះជាផ្នែកមួយនៃយុទ្ធវិធីរបស់ពួកមេបញ្ជាការអាមេរិកាំងនៅក្រុងសៃហ្គង ដើម្បីធ្វើឲ្យសមហេតុផលសំរាប់បើកការវាយប្រហារយោធាប្រឆាំងមកលើប្រទេសកម្ពុជា ។

លោកសឺន-សាន នាយករដ្ឋមន្ត្រីរបស់ព្រះអង្គ បានត្រូវផ្ដល់ពត៌មានឲ្យដឹងអំពីជំរំនេះដោយពួកអ្នកកាសែត មុនពេលអត្ថបទចេញផ្សាយ ។ ប្រតិកម្មដំបូងបង្អស់របស់គាត់ គឺមានការប្រយ័ត្នប្រយែងណាស់ សូម្បីតែនិយាយស្ដី ។ គាត់ពោលថា គាត់ត្រូវធ្វើការស៊ើបអង្កេតជាផ្លូវការមួយជាមុនសិន ។

សម្ដេច, ទោះបីយ៉ាងដូច្នេះក៏ដោយ, ត្រូវគេរាយការណ៍ឲ្យដឹងថា បានចោទប្រកាន់ពួកអ្នកកាសែតអំពីអំពើមានពុតត្បុត ដោយមានបន្ទូលថាភស្តុតាងទាំងអស់នោះគ្មានការពិត និងជំរំនោះទៀតសោតក៏មិនដឹងថាតើមានឬក៏អត់មានផងទេ ។

លោកនាយករដ្ឋមន្ត្រីបានត្រូវគេនិយាយប្រាប់ឲ្យដឹងថា បានទូលប្រាប់ទៅសម្ដេច អំពីអ្នកកាសែតជើងចាស់បីនាក់ដែលបានយកការណ៍យ៉ាងយូរនៅក្នុងស្រុកយួន យល់ថាជំរំនេះគឺពិតជាជំរំរបស់យៀកកុងគ្មានភ័ន្តច្រឡំសោះឡើយ ។

ភស្តុតាងរកឃើញ មានរួមទាំងឯកសារកងទ័ពសរសេរជាភាសាយួន និងថ្នាំពេទ្យផ្ដល់ឲ្យដោយពួកយួនខាងជើង ។ ថ្ងៃខែចុះនៅលើក្រដាស់សំរាប់កត់ហេតុ បញ្ជាក់ឲ្យដឹងថា ជំរំនេះបានត្រូវគេប្រើប្រាស់ជាច្រើនខែមកហើយ ចាប់តាំងពីខែកុម្ភៈឆ្នាំទៅមកម្លេះ ។

សម្ដេចបានធ្វើការអញ្ជើញដោយផ្ទាល់ខ្លួនព្រះអង្គ សុំឲ្យពួកអ្នកកាសែតទៅមើលដល់ព្រំដែន ដើម្បីស៊ើបអង្កេតការថ្កោលទោសអំពីការឆ្លងចូលមកនៃពួកយៀកកុង ។ គេមិនឃើញមានពួកកាសែតបស្ចឹមប្រទេស ដែលតែងស្នាក់នៅជារឿយៗក្នុងក្រុងភ្នំពេញទេ ហើយសម្ដេចក៏កម្រផ្ដល់នូវទិដ្ឋាការដល់ពួកអ្នកទាំងអស់នេះផងដែរ ។

ភាគច្រើនបានផ្ដល់ទិដ្ឋាការឲ្យក្នុងឆ្នាំនេះ ក៏ពីព្រោះដោយសារមកពីមានពិធីប្រារព្ធថ្ងៃបុណ្យឯករាជ្យ ដែលជាន់គ្នាទៅនឹងដំណើរទស្សនកិច្ចរបស់លោកស្រី Jacqueline Kennedy ប៉ុណ្ណោះ ។

ពួកមន្ត្រីអាមេរិកាំងបានថ្កោលទោសពីរឆ្នាំរួចមកហើយថា ប្រទេសកម្ពុជាត្រូវពួកយៀកកុងប្រើប្រាស់ជាជំរក ។ អស់រយៈច្រើនឆ្នាំ ដែលគេបានរៀបចំ<ដំណើរ> ឲ្យពួកអ្នកកាសែតបស្ចឹមប្រទេស ទៅពិនិត្យមើលជាញឹកញាប់ តែគេមិនប្រទះឃើញភស្តុតាងអ្វីជាដុំកំភួនសោះ ។

ក៏ប៉ុន្តែ ក្រៅពីក្រុមគ្រួសាររបស់សម្ដេចចេញ មនុស្សភាគច្រើននៅក្នុងទីក្រុងភ្នំពេញ ទាំងជនជាតិបរទេសនិងជនជាតិខ្មែរ ទទួលស្គាល់ការពិត អំពីការលបឆ្លងចូលនៃពួកយៀកកុងទាំងអស់នេះ ។

ពួកអាជ្ញាធរអាមេរិកាំងបានចង្អុលបង្ហាញឲ្យឃើញ យ៉ាងហោចណាស់នូវជំរំអចិន្ត្រៃយ៍ចំនួន២០កន្លែងដែរ ។ ភាគច្រើនស្ថិតនៅចម្ងាយ៥ម៉ៃល៍ (៨គ.ម.) ប៉ុណ្ណោះពីទល់ដែន ជាកន្លែងដែលកងទ័ពខ្មែរគ្មានធ្វើការយាមល្បាត និងជាកន្លែងដែលគ្មានប៉ុស្តិ៍អ្វីសំខាន់សោះ ។ ការថែទាំព្រំដែនស្ទើរតែផ្ដុកផ្ដាកទាំងស្រុងទៅលើកងឈ្លបនៅតាមភូមិ ដែលជាកម្លាំងមានការសង្ស័យស្ថិតនៅក្រោមគំនាប ឬការលបឆ្លងចូលនៃពួកយៀកកុង ។

ពួកអាជ្ញាធរមានសមត្ថកិច្ចនិយាយថា ពួកយៀកកុងធ្វើប្រតិបត្តិការយ៉ាងសម្ងាត់នៅក្នុងទឹកដីខ្មែរ ដូចគ្នានឹងនៅក្នុងស្រុកយួនដែរ ។ ពួកគេជ្រើសរើសរកទីកន្លែងណាមិនជួបទាហានខ្មែរជាពិសេសកន្លែងគ្មានមនុស្សនៅត្រង់ទិសខាងជើងឆៀងខាងកើត ដែលជាកន្លែងព្រំដែនជួបប្រសព្វគ្នានៃកម្ពុជា លាវ និងវៀតណាម ។

នៅទីនោះ ផ្លូវលំហូ-ជីមិញដែលចេញពីប្រទេសលាវ ត្រូវទៅជួបគ្នាជាមួយផ្លូវលំសីហនុនៅក្នុងស្រុកខ្មែរ ។ ក្នុងតំបន់ព្រៃដាច់ស្រយាលនេះ គេពុំឃើញមានបង្គោលសីមាអ្វីទាំងអស់ ហើយទាហានខ្មែរក៏ពុំដែលចូលទៅដល់ដែរ ។

ប្រភពបរទេសគ្មានលំអៀងនៅក្នុងទីក្រុងភ្នំពេញ បានទទួលស្គាល់ថា មានកម្លាំងយៀកកុងនៅក្នុងស្រុកខ្មែរពិតប្រាកដមែន ។ ភាគច្រើនពោលអះអាងថា ចំនួនកងទ័ពមានច្រើនជាងអ្វីដែលសម្ដេចសីហនុប៉ាន់ស្មាននោះទៅទៀត ។

ជំរំមួយមានរបងព័ទ្ធជុំវិញ និងមានការយាមឃ្លាំយ៉ាងមាំ បានត្រូវគេរាយការណ៍ថា បង្កើតឡើងជាយូរមកហើយ នៅតាមបណ្ដោយព្រំដែន

ខេត្តមណ្ឌលគិរី ទល់មុខនឹងតំបន់ខ្ពង់រាបប្រទេសវៀតណាម ។ ជំរបណ្តោះអាសន្ននិងកន្លែងឆ្លងកាត់ផ្សេងទៀត បានត្រូវគេរាយការណ៍ថាស្ថិតនៅក្នុងខេត្តមណ្ឌលគិរី និងភ្ជាប់ទៅខេត្តរតនគិរីលើផ្លូវលំសីហនុ ។ មន្ទីរពេទ្យមួយមានគ្រែអ្នកជម្ងឺចំនួន៤០០ ក៏បានត្រូវគេរាយការណ៍ថាស្ថិតនៅជិតក្រុងមេមត់ ក្នុងខេត្តកំពង់ចាម ។

ប្រភពនៅក្នុងក្រុងភ្នំពេញ ដែលតាមធម្មតាបដិសេធមិនព្រមឲ្យបញ្ចេញឈ្មោះ ជាអ្នកផ្តល់នូវពត៌មានអស់នេះ ។

តាមបណ្តោយព្រំដែនខេត្តកំពង់ចាម នៅត្រង់ចំការកៅស៊ូ ជារឿយៗចំនួន២០ភាគរយនៃកម្មករ ជាជនជាតិយួននិងភាគច្រើនជាសមាជិកទាហានយៀកកុង ។ ពួកកម្មករទាំងនេះតែងបាត់ខ្លួនជាច្រើនថ្ងៃ ក្នុងមួយលើកៗ ។ ពួកអ្នកចាត់ការចំការកៅស៊ូមានមន្ទិលសង្ស័យថា ពួកអ្នកទាំងអស់នេះនាំគ្នាឆ្លងព្រំដែនទៅបំពេញប្រតិបត្តិការ ។

ឡានកាម្ញុងចំការកៅស៊ូក៏បាត់ជាច្រើនថ្ងៃផងដែរ ទំនងចេញទៅដឹកស្បៀង គ្រាប់រំសេវ ថ្នាំពេទ្យ ។ គឺបរចុះតាមផ្លូវជាតិលេខ៧ ដែលស្របតាមបណ្តោយព្រំដែន រួចទម្លាក់ចុះដើម្បីផ្ទេរទៅឲ្យរទេះគោឬកង់ដឹកបន្តឆ្លងកាត់ព្រំដែនទៅមុខទៀត ។

ស្បៀង គ្រាប់រំសេវ និងថ្នាំពេទ្យរបស់យៀកកុង ក៏បានដឹកជញ្ជូនផងដែរតាមផ្លូវលេខ៧ ដោយក្រុមហ៊ុនឡានកាម្ញុងឯកជន ដែលមួយចំនួននោះត្រួតត្រាដោយជនជាតិចិន ។ គេគ្មានអ្វីពិសេសជាអាថ៌កំបាំង អំពីការដឹកជញ្ជូននេះទេ ។ នៅតាមផ្លូវក្រាលថ្ម មានប៉ុស្តិ៍ប៉ូលីសនិងទាហានពីរ-បីប៉ុណ្ណោះ និងស្ថិតនៅឆ្ងាយដាច់សង្វែងពីគ្នា ។ ព្រៃឈើនៅសង្ខាងផ្លូវ អាចជួយបិទបាំងមិនឲ្យគេមើលឃើញការដឹកជញ្ជូនផងដែរ ។

ទោះបីស្តេចសីហនុផ្តល់នូវការគាំទ្រយ៉ាងពេញទំហឹង ទាំងផ្លូវចិត្តនិងនយោបាយ ចំពោះរណសិរ្សរំដោះជាតិនៃពួកយៀកកុងយ៉ាងណាក៏ដោយ ព្រះអង្គតែងតែទទូចថា ការគាំទ្ររបស់ព្រះអង្គក៏ពុំបានពង្រីកទៅដល់វិស័យយោធានោះឡើយ ។

ពួកអាជ្ញាធរមានសមត្ថកិច្ចខ្លះនៅក្នុងទីក្រុងភ្នំពេញបានពោលអះអាងថា សម្តេចពុំមែនមិនដឹងអំពីទឹកដីរបស់ព្រះអង្គត្រូវពួកយៀកកុងប្រើប្រាស់នោះទេ ។ អ្នកផ្សេងទៀតនិយាយថា សម្តេចមានចេតនាធ្វើមិនដឹងមិនឮអំពីសកម្មភាពរបស់ពួកយៀកកុង ជាពិសេសនៅក្នុងព្រៃនៃខេត្តទិសខាងជើង ជាទីកន្លែងដែលរដ្ឋាភិបាលរបស់ព្រះអង្គមានការត្រួតត្រាដ៏តិចតួចបំផុត ។ នៅក្នុងខេត្តទិសខាងត្បូង ជាប់ព្រំដែនយួនទល់នឹងតំបន់ដីសណ្តរទន្លេមេគង្គ បញ្ជារបស់ព្រះអង្គមិនឲ្យពួកយៀកកុងឆ្លងកាត់មានប្រសិទ្ធិភាពយ៉ាងគួរសមដែរ ។

ស្តេចសីហនុមានបន្ទូលជាច្រើនលើកក្នុងពេលថ្មីៗនេះថា ទាហានទាំង៣៥,០០០នាក់របស់ព្រះអង្គ ដែលភាគច្រើនដាក់រាយចាប់ពីព្រំដែនជាមួយថៃទៅទិសខាងលិចនោះ ពុំអាចបិទព្រំដែនប្រវែង៥០០ម៉ៃល៍ (៨០០គ.ម.) ជាមួយយួនបានឡើយ ។ ព្រះអង្គសួរថា តើហេតុអីបានជាអាមេរិកាំងរំពឹងចំពោះព្រះអង្គឲ្យបិទព្រំដែនយ៉ាងដូច្នេះ នៅក្នុងពេលដែលកងទ័ពអាមេរិកាំងចំនួន១,០០០,០០០នាក់ ជាមួយនិងកងទ័ពយួនខាងត្បូង ពុំមានលទ្ធភាពធ្វើកិច្ចការនេះបានផងនោះ ។

កាលពី៨ខែមុន, ព្រះអង្គបានបញ្ជាទៅពួកមេបញ្ជាការកងទ័ពរបស់ព្រះអង្គ ឲ្យបណ្តេញពួកបរទេសឈ្លានពានទាំងអស់ចេញពីទឹកដីខ្មែរ ។ ពួកមេបញ្ជាការប្រចាំតំបន់ បាន<សុំ>ទៅកងឯកភាពយៀកកុងដែលឆ្លងចូលមក ឲ្យវិលត្រឡប់ចាកចេញទៅវិញ ។ គេគ្មានឃើញសេចក្តីរាយការណ៍ពីអំពើឈ្លានពានរបស់យៀកកុងផ្ញើមកភ្នំពេញទេ តែផ្ទុយទៅវិញគេប្រទះឃើញសេចក្តីរាយការណ៍យ៉ាងពិស្តារ នូវគ្រប់អំពើឈ្លានពាននៃយន្តហោះនិងកងទ័ពអាមេរិកាំងឬយួនខាងត្បូង ។

ព្រះអង្គក៏បានសុំផងដែរ កាលពីឆ្នាំទៅមិញ ឲ្យមានការពង្រឹងនៃគណៈកម្មាធិការត្រួតពិនិត្យអន្តរជាតិ (ICC) ដែលបានរៀបចំបង្កើតឡើងដោយសន្និសិទនៅទីក្រុងហ្សឺណែវ ស្តីអំពីឥណ្ឌូចិន ។ គណៈកម្មាធិការនេះរួមមាន ប្រទេសប៉ូឡូញ, ឥណ្ឌា និងកាណាដា ។ សហភាពសូវៀតជាមួយប្រទេសអង់គ្លេស ដែលជាសហប្រធានសន្និសិទហ្សឺណែវ បានបោះឆ្នោតលើផែនការពង្រីកគណៈកម្មាធិការត្រួតពិនិត្យអន្តរជាតិនេះ ។

ICC អាចធ្វើការស៊ើបអង្កេតពាក្យតវ៉ារបស់ខ្មែរតែប៉ុណ្ណោះ ។ គេបានពិនិត្យរកឃើញយន្តហោះអាមេរិកាំង ទម្លាក់គ្រាប់បែកទៅលើភូមិនៅតាមព្រំដែន និងបានបញ្ជាក់អំពីរឿងមួយចំនួនទៀត ។ ក៏ប៉ុន្តែផ្ទុយទៅវិញ គេមានសេចក្តីរាយការណ៍តែពីរគត់ប៉ុណ្ណោះ អំពីអំពើរំលោភរបស់យៀកកុង ដែលមានលទ្ធផលជាអវិជ្ជមានទាំងពីរលើក ។៚

## ឯកសារប្រវត្តិសាស្ត្រ



បូដួយទាំង៥៣នាក់ដែលកងទ័ពខ្មែរចាប់ខ្លួននៅតាមបណ្តោយព្រំដែន បានត្រូវស្តេចសីហនុបញ្ជាឲ្យដោះលែងកាលពីថ្ងៃទី២៩ កក្កដា ១៩៦៩

# ការសម្ងាត់

## សេចក្តីរាយការណ៍សម្ងាត់បោះពុម្ពផ្សាយក្រោមបញ្ជានៃសម្តេចសីហនុក្នុងទស្សនាវដ្តីប្រចាំខែ<ឡឹសង្គម>

( លេខខែមិថុនា ឆ្នាំ១៩៦៩ )

## សម្ភាសន៍នៃលោកឧត្តមសេនីយ៍ឯក លន់_នល់ ជាមួយលោកង្វៀង_ធួង, រដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងលោកង្វៀង_វ៉ាន់ហ៊ីវ, រដ្ឋទូតនៃរណ_សិរ្សរំដោះជាតិ

( បកប្រែក្រៅផ្លូវការ )

ដកស្រង់ចេញពី <ឯកសារស្តីអំពីអំពើឈ្លានពាន នៃយៀកកុង-យៀកណាមខាងជើងមកលើកម្ពុជា-ឆ្នាំ១៩៧០> បោះពុម្ពផ្សាយដោយក្រសួងឃោសនាការជាតិក្រុងភ្នំពេញ

តមកពីលេខមុន...

តែផ្ទុយទៅវិញ កងទ័ពរបស់លោកមិនត្រឹមតែមិនព្រមចាកចេញប៉ុណ្ណោះទេ ពួកលោកថែមទាំងបាញ់រះមកលើកងទ័ពយើងរាល់លើក ហើយនៅពេលចុងក្រោយនេះបានបង្ហាញអាកប្បកិរិយា ដែលពុំមែនចេញមកពីមិត្តថែមទៀតផង ។

ជាបន្ថែម, ពួកមនុស្សរបស់លោកបានត្រូវយើងប្រាប់ឲ្យដឹងជាច្រើនលើករួចមកហើយ សុំធានាឲ្យចាកចេញពីទឹកដីរបស់យើង ។ តែទោះបីដូច្នេះក៏ដោយ, ការពិតពួកលោកនៅតែក្រាញស្ថិតនៅទីកន្លែងដដែលនោះ និងពង្រឹងឲ្យកាន់តែខ្លាំងថែមទៀត ។

ដើម្បីជាការគាំទ្រនូវអ្វីខាងលើនេះ ព្រះរាជបំរើបានបង្ហាញឲ្យពួកគេឃើញនូវរូបថតទាហានយៀកណាមចាប់ខ្លួនបានបីនាក់ នៅទិសខាងជើងបាកាប់ (បខាំ), ៧នាក់ចាប់ខ្លួនបាននៅមណ្ឌលគិរី, ទាហានយៀកកុងស្លាប់នៅក្នុងជួរខ្មែរក្រហម ដែលប្រកាសឲ្យដឹងអំពីចេតនារបស់ពួកគេអំពីគ្រឿងសម្ភារ:, អាវុធយុទ្ធភ័ណ្ឌ ព្រមទាំងឧបករណ៍រឹបអូសយកបាននៅលើខ្លួនមនុស្សទាំងអស់នោះ នូវរបស់របរមានលក្ខណ:ជាយៀកណាម និងមានគំរូជាចិន ។

II- <u>ការវាយប្រហារយ៉ាងចំហនៃកងទ័ពយៀកណាមខាងជើង និងយៀកកុង ប្រឆាំងមកលើកងទ័ពរបស់យើង</u> ៖

ព្រះរាជបំរើបង្ហាញឲ្យពួកគេឃើញនូវផែនទី ដែលបានភ្ជាប់មកជាមួយនេះ ដើម្បីថ្វាយសម្តេចសហជីវិនពិនិត្យមើល អំពីចំណុចទាំងអស់ដែលកងទ័ពយើងពើបប្រទះ នាថ្ងៃដំបូងនៃប្រតិបត្តិការ ។ សេចក្តីអត្ថាធិប្បាយលើករណីនិមួយៗដូចមានតទៅនេះ ៖

១- **នៅរតនគិរី** ៖

«ដើម្បីរៀបចំរដ្ឋបាលឡើងវិញនៅបខាំ, កម្លាំងទ្រទ្រង់ខាងយើងរហូតមកទល់ពេលឥឡូវនេះ មិនទាន់ចាកចេញពីផ្លូវនៅឡើយ ។ នេះគឺបង្ហាញឲ្យឃើញអំពីចំណុចកើតហេតុនៅលើសំណៅ, គឺខាងកងទ័ពរបស់លោកធ្វើអន្តរាគមន៍ប្លុករាំងខ្ទប់សកម្មភាពរបស់យើង, ហើយនិងកំពុងប្រើប្រាស់ទឹកដីរបស់យើងជាមួយគ្នាផងដែរ ។

ឆ្ពោះទៅទិសខាងជើង, កងទ័ពយើងសងផ្លូវដើម្បីទាក់ទងគ្នា, តែកងទ័ពរបស់លោកបានបំផ្លាញម៉ាស៊ីនជីកដី ហើយនិងបើយោងតាមការប្រកាសរួមនៃពួកខ្មែរលើជាមួយប្រជាពលរដ្ឋរស់នៅទីនោះ គឺបញ្ចៀសមិនឲ្យគេនាំជំនួយទៅជួយដល់រដ្ឋបាលសង្គមក្នុងកន្លែងធ្វើការនេះ ដោយប្រើប្រាស់នូវមធ្យោបាយគ្រប់បែបយ៉ាង មានរហូតដល់ការបាញ់សម្លាប់ធ្វើជាគំរូ ដល់ពួកអ្នកចចេសរឹងរូស ដែលគ្នាមិនចង់ចូលរួមចំណែកជាមួយខាងលោក, មានការប្រើកម្លាំងទ័ព, ការបិតប្រកាសនៅតាមទីកន្លែងសង្គម និងនៅតាមទីរដ្ឋបាលនានា» ។

ព្រះរាជបំរើលើកចំណុចនេះបញ្ជាក់ទៅពួកគេថា ពួកអ្នកទោសនិងមនុស្សស្លាប់ដែលបង្ហាញនៅក្នុងរូបថត គឺបានធ្វើនិងសម្លាប់ជាបន្តបន្ទាប់គ្នា នៅក្នុងពេលប៉ះទង្គិចយ៉ាងខ្លាំងក្លានិងយ៉ាងធ្ងន់ធ្ងរ ។ បញ្ជីយ៉ាងវែងនៃអ្នកស្លាប់និងរបួសខាងយើង ក៏បានលើកយកមកបង្ហាញឲ្យឃើញផងដែរក្នុងពេលនិយាយគ្នានោះ សំរាប់ធ្វើជាភស្តុតាងពុំអាចបដិសេធបានដែលខាងយើងជាអ្នករងគ្រោះ នៅក្រោមអំពើវាយប្រហារពីសំណាក់កងទ័ពយៀកណាមស្ថិតនៅក្នុងតំបន់នោះ ។

២- **តំបន់ផ្សេងទៀត – កំពង់ចាម, ព្រៃវែង, ស្វាយរៀង** ៖

នៅចន្លោះឧប្បត្តិហេតុកត់ត្រាទុកជាច្រើនផ្សេងទៀតរហូតទល់ពេលនេះ ដែលបានធ្វើឲ្យបាត់បង់នូវអាយុជីវិតមនុស្សជាច្រើនរយនាក់ និងធ្វើឲ្យរបួសមួយចំនួននៅក្នុងចំណោមសមាជិកនៃកងយោធពលខេមរភូមិន្ទ, កងរក្សាខេត្ត, ពួកអ្នករាជការស៊ីវិលរបស់យើង ព្រមទាំងក្នុងចំណោមប្រជាពលរដ្ឋស្លូតត្រង់ ដែលមានស្ត្រីនិងកូនក្មេង, ព្រះរាជបំរើបានលើកឡើងមកបញ្ជាក់បង្ហាញអំពីការវាយប្រហារនៅអន្លង់ក្រែស (កំពង់ចាម), នៅសន្ទៃ (ព្រៃវែង) ដែលបណ្តាលឲ្យមានមនុស្សស្លាប់មួយចំនួន រួមទាំងចៅហ្វាយប៉ុស្តិ៍សន្ទៃនៅក្នុងនោះផងដែរ ។ ការធ្វើអត្ថាធិប្បាយនៃអំពើវាយប្រហារនេះ បានធ្វើជាភាសាយៀកណាម ។

នៅក្នុងការប៉ះទង្គិចគ្នាកាលពីពេលថ្មីៗនៅត្រង់កន្លែងតាម៉ូ (ប៉ប៉ែត) ទិសខាងជើងបរិត, កម្លាំងទ័ពរបស់យើងបានបាត់បង់ (មនុស្សស្លាប់និងរបួស) កាន់តែច្រើនឡើងៗគ្មានឈប់ឈរ ។ សូម្បីតែកាលពីព្រឹកមិញនេះ យើងបានទទួលពត៌មានមកថា កងទ័ពរបស់លោកបានពង្រឹងកម្លាំង ពីមនុស្សចំនួនប្រហែល១,០០០នាក់ ឡើងទៅដល់ចំនួនជាង២,០០០នាក់ ។

យើងលើកចំណុចនេះដើម្បីបញ្ជាក់ថា កងទ័ពយើងពុំបានធ្វើអ្វីទេក្រៅអំពីទៅកាន់ទីនោះ សុំឲ្យលោកដកកងទ័ពរបស់លោកថយចេញពីទឹកដីរបស់យើង ។ ជាការឆ្លើយតប, យើងបានទទួលនូវការបាញ់ប្រហារពី

សំណាក់កងទ័ពរបស់លោក ដែលមិនគោរពច្បាប់អន្តរជាតិ និងការប្រកាសពីរដ្ឋាភិបាលរបស់លោកទាល់តែសោះ ។

៣- <u>ការគាំទ្រនៃយៀកកុងនិងកងទ័ពយៀកណាមខាងជើង ចំពោះក្រុមខ្មែរក្រហម</u> ៖

**លើផែនការហ្វឹកហ្វឺនអប់រំ - ការបញ្ចូលក្រុបខ័ណ្ឌ និងការគាំទ្រ ៖**

១- ក្រោយការអនុវត្តលក្ខន្តិកៈកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវឆ្នាំ១៩៥៤, មានជនជាតិខ្មែរជាច្រើនបានហ្វឹកហ្វឺននៅក្នុងសាលារបស់លោកនៅវៀតណាមខាងជើង ។ ចាប់តាំងពីមានការបះបោរនៅសំឡូត យើងបានកត់សម្គាល់ឃើញថា ខ្មែរក្រុបខ័ណ្ឌទាំងនេះដែលត្រឡប់មកកម្ពុជាវិញ គឺសុទ្ធសឹងជាមនុស្សក្រុបខ័ណ្ឌរបស់ក្រុមខ្មែរក្រហម (អតីតខ្មែរវៀតមិញដែលស្ថិតនៅត្រង់ទីកន្លែងនោះតែម្តង) ។ ការបញ្ជាក់នេះផ្អែកទៅលើការពិតមួយចំនួន ។ ពួកមេខ្មែរក្រហមដែលមកចុះចូលខាងយើងក៏បានជួយបង្ហាញនូវកន្លែងលាក់អាវុធយ៉ាងសន្ធឹកសន្ធាប់ និងដែលបន្សល់ទុកដោយពួកវៀតមិញ មុនពេលចាកចេញរបស់ខ្លួននាឆ្នាំ១៩៥៤ ។

- ពួកកងទ័ពមានខ្មែរក្រហមនៅក្នុងនោះ ដែលបានធ្វើការវាយប្រហារអន្លង់ក្រែសនិងសន្ទៃ (កណ្តុរជ្រូ), ពេលដកថយចូលទៅក្នុងទឹកដីយៀកណាម គឺថយទៅជាមួយកងទ័ពរបស់លោក ។ លើសពីនេះទៅទៀត នៅក្នុងពេលវាយប្រហារនៅកណ្តុរជ្រូ ពួកក្រុបខ័ណ្ឌរបស់លោកជាចេញបញ្ជាជាភាសាយៀកណាម ទៅលើមួយកងផ្នែកខាងខ្មែរដែលស្ថិតនៅជាមួយនិងមួយកងផ្នែកខាងយៀកណាម ។

- វាជាការចាំបាច់ដើម្បីគូសបញ្ជាក់ឲ្យលោកចាប់អារម្មណ៍ផងដែរថា កងទ័ពទាំងនេះដែលធ្វើការវាយប្រហារទៅលើប្រជាពលរដ្ឋខ្មែរ និងទៅលើទីតាំងរបស់យើងនៅតាមព្រំដែន គឺគាំទ្រដោយកងទ័ពរបស់លោកដែលនៅសល់និងប្រកបដោយអាវុធយ៉ាងខ្លាំងក្លា ដូចជាករណីនៅក្នុងខេត្តពោធិសាត់, កំពង់ស្ពឺ, កំពត, កំពង់ចាម, ឆ្លូង ជាដើម... ។

**លើផែនការអាវុធយុទ្ធភ័ណ្ឌ ៖**

«ជាភាគច្រើន, ពួកខ្មែរក្រហមប្រដាប់ដោយអាវុធដ៏ទំនើបៗ និងធ្វើនៅស្រុកចិន ។ ការគាំទ្រនិងការឧបត្ថម្ភរបស់លោកចំពោះពួកខ្មែរក្រហម បានរួមផ្សំគ្នាជាមួយការឃោសនារបស់ពួកគេ ។ ពួកគេអះអាងក្នុងពេលថ្មីៗជាមួយប្រជាពលរដ្ឋខ្មែរថា ដោយមានការគាំទ្រពីកងទ័ពយៀកណាមខាងជើងនិងយៀកកុងចំពោះចលនារបស់ពួកគេ ពួកគេគ្មានអ្វីភ័យខ្លាចទៀតឡើយ ។ កម្លាំងនៃការគាំទ្រនិងការឧបត្ថម្ភ ព្រមទាំងគ្រឿងសម្ភារៈយ៉ាងល្អពីលោក ពួកនេះបានធ្វើការបំពានមកលើទីកន្លែងរបស់យើង និងធ្ងន់ជាងនេះទៅទៀត **ធ្វើការប្រឆាំងចំពោះសម្តេចសហជីវិន ដែលជាអ្នកកំពុងជួយលោកព្រមទាំងរដ្ឋាភិបាលរបស់លោក ដែលព្រះអង្គបានគោរពចាត់ទុកជាមិត្តយ៉ាងធំមួយ** ។

លើសអំពីនេះទៅទៀត, ចំពោះមុខស្ថានភាពដ៏ធ្ងន់ធ្ងរនេះ ប្រជាពលរដ្ឋខ្មែរសុំមិនយល់ទាល់តែសោះថា តើហេតុអ្វីបានជាប្រជាពលរដ្ឋយៀកណាមខាងជើងនិងយៀកកុងទទួលស្គាល់ពួកខ្មែរក្រហម ជាងសម្តេច ។

គោលជំហរបច្ចុប្បន្នរបស់យើងមានការពិបាកខ្លាំងណាស់ គឺយើងពុំអាចពន្យល់ខ្លួនយើង ថាតើហេតុអ្វីបានជាលោកធ្វើទាំងអស់នេះប្រឆាំងជាមួយយើង ។

កងទ័ពរបស់យើង ព្រមទាំងប្រជាពលរដ្ឋរបស់យើងផងដែរមិនយល់ទាល់តែសោះអំពីរឿងនេះ ។

ហើយយើងក៏ពុំអាចរកអ្វីឲ្យច្បាស់ពិតប្រាកដ ដើម្បីពន្យល់នូវការពិតចំពោះពួកគេបានឡើយ » ។

នេះជាចម្លើយនិងប្រតិកម្មនៃឥស្សរជនទាំងនេះ ៖




ផែនទីបង្ហាញទីតាំងមូលដ្ឋានកងទ័ពយៀកណាមខាងជើងនិងយៀកកុង ៖ ពណ៌ក្រហម (មុនថ្ងៃ៨ មិនា ១៩៧០), គំនូសឆ្នូត (ក្រោយថ្ងៃ៨ មិនា ១៩៧០) ដែលមានទាហានទាំងអស់ចំនួន ៥៤,៥០០នាក់ ។

**ចម្លើយនិងប្រតិកម្មរបស់លោក ង្វៀង-ធួង, រដ្ឋទូតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ៖**

គាត់មានសេចក្តីសោកស្តាយចំពោះឧប្បត្តិហេតុដែលបានកើតឡើងនេះ ហើយគូសបញ្ជាក់ថា នយោបាយរបស់រដ្ឋាភិបាលគាត់ គឺសាងមិត្តភាពជាមួយប្រទេសទាំងអស់ក្នុងពិភពលោក (ជាពិសេសជាមួយកម្ពុជា), ដែលជាអ្នកជិតខាងគ្នាដ៏ល្អ, គ្មានជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងគ្នាទៅវិញទៅមក... ជាញឹកញាប់អះអាងដោយពួកមេដឹកនាំរដ្ឋាភិបាលរបស់គាត់ដោយបញ្ជាក់ថាបានធ្វើស្របតាមពាក្យសំដីរបស់ខ្លួន **ហើយក៏សូមអរព្រះគុណសម្តេចសហជីវិននិងរាជរដ្ឋាភិបាល ចំពោះការគាំទ្ររបស់យើង និងការឧបត្ថម្ភរបស់យើងដល់ប្រជាជនវៀតណាម ធ្វើការប្រយុទ្ធដើម្បីឯករាជភាពនៃប្រទេសរបស់គាត់** ។

គាត់មានបារម្ភថា ឧប្បត្តិហេតុទាំងអស់នេះជាស្នាដៃនៃកងកម្លាំងជួរទី៥រដ្ឋាភិបាលក្រុងសៃហ្គង ឬក៏ពួកអាមេរិកាំង ហើយស្ថានភាពដ៏ពិតប្រាកដនោះ វាជាលទ្ធផលចេញមកពីសង្គ្រាមនៅវៀតណាមខាងត្បូងដែលក្នុងករណីចាំបាច់ខ្លះកើតឡើងចំពោះកងទ័ពនៅក្នុងពេលធ្វើប្រតិបត្តិការ, គាត់ពោលបន្ថែម ។ ពួកអ្នកផ្តល់ពត៌មានពុំដែលជូនពត៌មានពិស្តារអំពីឧប្បត្តិហេតុទាំងអស់នេះទេ ។ លោករដ្ឋទូតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមប្រកាសថា គាត់នឹងទៅសាកសួរពត៌មានបន្ថែមពីរដ្ឋាភិបាលរបស់គាត់អំពីរឿងនេះ ។

ព្រះរាជបំរើបានបញ្ចប់ការសន្ទនាជាមួយលោក ង្វៀង-ធួង ដោយធ្វើការគូសបញ្ជាក់ចំពោះគាត់ថា ៖ សកម្មភាពនិងអាកប្បកិរិយានៃកងទ័ពយៀកណាម ពុំបានសមស្របតាមពាក្យសំដីនិងការប្រកាសរបស់ពួកមេដឹកនាំនៅយៀកណាមខាងជើងទេ ។

**ចម្លើយនិងប្រតិកម្មរបស់លោក ង្វៀង-វ៉ាន់ហ៊ីវ រដ្ឋទូតនៃរណសិរ្សរំដោះជាតិ ៖**

ចំណុចសំខាន់ គឺមានដូចគ្នានឹងចម្លើយហើយនិងប្រតិកម្មរបស់លោក ង្វៀង-ធួង ដែរ ។ ឥស្សរជនរូបនេះប្រកាសឲ្យដឹងចំពោះព្រះរាជបំរើថា ពេលឧប្បត្តិហេតុកើតឡើងរវាងកងទ័ពរបស់គាត់និងកងទ័ពយើង, តំណាងនៃរណសិរ្សរំដោះជាតិនៅភ្នំពេញ តែងមានទម្លាប់សុំទៅប្រេស៊ី

ដីយ៉ូម ឲ្យធ្វើការស៊ើបអង្កេត ហើយទាហានយៀកកុងមានកំហុសតែងតែយកទៅធ្វើទោសជាទម្ងន់ ។ ក្នុងករណីនៅតាម៉ូ បើយោងតាមសំដីរបស់គាត់និយាយថា កងកម្លាំងប្រចាំការនៃយោធពលខេមរភូមិន្ទមួយកងយ៉ាងខ្លាំង បានធ្វើប្រតិបត្តិការប្រឆាំងគិលានដ្ឋានយៀកកុងមួយ ។

ព្រះរាជបំរើបានចង្អុលប្រាប់ទៅលោក ង្វៀង-វ៉ាន់ហ៊ីវ ថា ៖ ចំពោះរឿងនៅតាម៉ូ (ស្វាយរៀង) យោងតាមព្រិត្តិការណ៍ដែលបានកើតឡើង គឺលើសពីគិលានដ្ឋានមួយនោះទៅទៀត កងទ័ពរបស់លោកជាច្រើនប្រដាប់ដោយអាវុធ បានធ្វើការកាត់ផ្តាច់តំបន់ជាយូរពេលមកហើយ ។ ទ័ពប្រចាំការនៃកងយោពលខេមរភូមិន្ទ គ្រាន់តែបំពេញករណិយកិច្ចរបស់ខ្លួន តម្រូវឲ្យកងទ័ពរបស់លោកដកថយចេញពីទឹកដីខ្មែរ ដែលកងទ័ពលោកបានឈ្លានពានជាច្រើនថ្ងៃមកហើយប៉ុណ្ណោះ ។

ជាមួយគ្នាផងដែរ ចាប់ពីដំបូងដៃមក កងយោធពលខេមរភូមិន្ទ, ប្រជាពលរដ្ឋខ្មែរ ក៏បានបាត់បង់នូវអាយុជីវិតនិងរបស់របរជាច្រើន ។

- ហើយចំពោះស្ថានភាពបច្ចុប្បន្ននេះ ប្រជាពលរដ្ឋខ្មែរទាំងអស់ក៏ចង់ដឹងដែរថា តើនរណាជាម្ចាស់ស្រុកខ្មែរ (រវាងលោកនិងយើង) ។

ទូលព្រះបង្គំបានសង្កត់បញ្ជាក់ចំពោះគាត់ផងដែរថា ចំពោះស្ថានភាពដ៏ធ្ងន់ធ្ងរនេះ ក៏បានថ្លែងប្រាប់គេឲ្យបានដឹងនៅក្នុងសន្និសិទសារពត៌-មាន ធ្វើឡើងដោយសម្តេចសហជីវិនរួចហើយ ។

ការសន្ទនាគ្នាចប់សព្វគ្រប់នៅវេលាម៉ោង ១៩:២៥ នាទី ។

ពាក្យសំដីទោះបីយ៉ាងណាកកក្តៅសមល្មម ទាំងសង្វាងក្នុងការប្តូរផ្តងគ្នាទាំងវិញទៅមក នៅចំពោះមុខសភាពការណ៍នានា ។៚

( កកន ៖ ការសន្ទនាគ្នាខាងលើរវាងលោកឧត្តមសេនិយលន់-នល់ ជាមួយរដ្ឋទូតយៀកណាមខាងជើងនិងយៀកកុង បញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ អំពីការអនុញ្ញាតរបស់ស្តេចសីហនុ ឲ្យពួកនេះតាំងមូលដ្ឋានទ័ពនៅលើទឹកដីខ្មែរ ។ បន្ទាប់ពីបានក្រឡេកឃើញស្ថានការណ៍កាន់តែដាបទៅៗ ដោយពួកយៀកណាមខាងជើងនិងយៀកកុងក្រាញមិនព្រមដកថយទៅវិញ ទើបស្តេចសីហនុបញ្ជាឲ្យលោកឧត្តមសេនិយលន់-នល់ចាត់ការបណ្តេញពួកវាចេញពីទឹកដីខ្មែរ ។ ក៏ប៉ុន្តែ... កិច្ចសន្យាបានធ្វើរួចទៅហើយ ជាពិសេសលុយកាក់ក៏បានប្រគល់គ្រប់ចំនួនអស់ហើយដែរ តើរឿងអ្វីកងទ័ពយៀកណាមខាងជើងនិងយៀកកុង ត្រូវដកថយយ៉ាងងាយស្រួលនោះ ? ។ នេះហើយ... ជាដំរេះជិះកឯងរបស់ស្តេចសីហនុ ដែលស៊ីជោរចាញ់កលខ្មាំង ។ ក៏ប៉ុន្តែរឿងអាស្រូវដ៏ធ្ងន់ធ្ងរជាងនេះទៅទៀតនោះ គឺនៅក្រោយពេលស្តេចសីហនុទម្លាក់អំរែកគ្រោះថ្នាក់នេះទៅឲ្យលោកលន់-នល់បន្តិចមក ព្រះអង្គក៏ស្រាប់តែហក់ទៅនៅខាងខ្មាំងជាសត្រូវស្ទួរពូជរបស់ខ្មែរ ដែលព្រះអង្គជាអ្នកបញ្ជាឲ្យបណ្តេញទៅវិញ ។ យើងនៅចាំសំដីរបស់ស្តេចសីហនុ ពន្យះកងទ័ពយៀកណាមខាងជើងនិងយៀកកុងឡុងៗពីប៉ៃកាំង ឲ្យស្ទុះទៅផ្តិលផ្តាច់អាយុជីវិតប្រជារាស្ត្រខ្លួនឯង បំផ្លិចបំផ្លាញទ្រព្យសម្បត្តិជាតិសឹងពាយអស់ពីនគរ ។ ពាក្យសំដីនេះស្តាប់ឮទៅហើយគួរឲ្យព្រឺក្បាលក្រៃលែង ។

ចំពោះពួកខ្មែរក្រហមវិញក៏ដូចគ្នាដែរ (ឃួនជាអ្នកបំពាក់អាវុធបំពាក់ស្មារតីឲ្យពួកនេះ) ស្តេចសីហនុ ដែលកាលពីដំបូងដៃជាអ្នកប្រឆាំងពួកនេះ ក៏ត្រឡប់ទៅចាក់ចេកចាក់ស្ករជាមួយគ្នា ធ្វើការបង្ហូរឈាមខ្មែររហូតក្លាយជា<ទីលានពិឃាត> ដោយអូសទាញស្រុកខ្មែរ ឲ្យធ្លាក់ទៅក្នុងនរកនៃសតវត្សទី២០ដ៏គួរឲ្យស្លុតរន្ធត់អស្ចារ្យ ។

នេះហើយជាវាសនារបស់ខ្មែរ ដែលមានស្តេចចោលម្សៀត (!!)